**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ១៤ **អយក.**សសរ

# សេចក្ដីសម្រេច

# ស្ដីពី

# ការតែងតាំងអ្នកនាំពាក្យប្រចាំក្រសួងអប់រំ យុវជន និងកីឡា

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១.-**

ត្រូវបានប្រគល់ភារកិច្ចជូនលោក **រស់ សាលីន** ជាអ្នកនាំពាក្យរបស់ក្រសួងអប់រំ យុវជន និងកីឡា បន្ថែមលើមុខងារបច្ចុប្បន្ន។

**ប្រការ ២.-**

អ្នកនាំពាក្យរបស់ក្រសួងអប់រំ យុវជន និងកីឡា មានតួនាទីនិងភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- ផ្ដល់ព័ត៌មានឆ្លើយតបអំពីក្រសួងអប់រំ យុវជន និងកីឡាទៅមជ្ឈដ្ឋានដែលមានសេចក្ដីត្រូវការ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- ស្រាយបំភ្លឺចំណោទបញ្ហានានាដែលកើតមានឡើងចំពោះក្រសួងអប់រំ យុវជន និងកីឡា
- សហការជាមួយគ្រប់នាយកដ្ឋានជំនាញក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡាក្នុងការប្រមូលព័ត៌មានដើម្បីឆ្លើយតបទៅមជ្ឈដ្ឋាននានា
- រាយការណ៍ជូនថ្នាក់ដឹកនាំអំពីលទ្ធផលការងារដែលបានអនុវត្ត
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៣.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធានអង្គភាពពាក់ព័ន្ធទាំងអស់ និងសាមីខ្លួន ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៤

**កន្លែងទទួល៖**

- គ្រប់អង្គភាពក្រោមឱវាទក្រសួង អ.យ.ក. "ដើម្បីជូនជ្រាប"
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា.នីតិកម្ម

**បណ្ឌិត ហង់ ជួន ណារ៉ុន**